# ព្រះវិហារវត្តខ្នុរ

វត្ត ពោធិព្រឹក្ស ហៅវត្តខ្នុរ ស្ថិតនៅភូមិខ្នុរ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ អំពីប្រវត្តិនៃការកកើតវត្តនេះ គឺពុំមានសំណេរអ្វីមកបញ្ជាក់នោះទេ គ្រាន់តែយើងដឹងថា ប្រជាជននៅក្នុងតំបន់គោរពប្រតិបត្តិខ្ពស់លើវត្តខ្នុរនេះ តាំងពីដើមរៀងមក។ បើយើងសង្កេតទៅលើការកសាងសំណង់ជាច្រើនទាំងចាស់ ទាំងថ្មី និងមានសំណង់ចាស់មួយកសាងពីឥដ្ឋបូកស៊ីម៉ង់ប្រក់ក្បឿង ដែលបច្ចុប្បន្នជាកន្លែងដាក់ទូក។ នៅក្នុងបរិវេណនៃវត្តនេះក៏ឃើញមានព្រះវិហារចាស់មួយ ដែលស្ថិតនៅខាងកើតនៃព្រះវិហារថ្មី។ ព្រះវិហារចាស់នេះកសាងក្បែរមាត់ទន្លេ ហើយប្រហែលជាសាងឡើងក្នុងកំឡុងដើមស.វ.ទី២០ ដ្បិតឃើញចារឹកលើជញ្ជាំងដាក់ថាឆ្នាំ១៩១៦ ដែលជាឆ្នាំស្ថិតក្នុងរជ្ជកាលព្រះករុណា ព្រះបាទសម្ដេចព្រះ ស៊ីសុវត្ថិ ចមចក្រពង្ស ព្រះរាជានុកោដ្ឋ និងជាពេលដែលប្រទេសកម្ពុជាស្ថិតក្រោមអាណាព្យាបាលបារាំង។ បើគិតពីអាយុកាលនៃសំណង់វិហារចាស់នេះរហូតមកដល់បច្ចុប្បន្នគឺ ១០៥ឆ្នាំ ដែលយើងអាចនិយាយថាជាសំណង់បេតិកភណ្ឌបាន[១]។ វិហារនេះ កសាងនៅលើខឿនរាងទ្រវែង ហើយបែរមុខទៅទិសខាងកើត។

សំណង់ព្រះវិហារ គឺជាសំណង់រៀបឥដ្ឋ បូកស៊ីម៉ង់ នឹងប្រក់ក្បឿង មានទំហំតូចល្មម ដែលជាលក្ខណៈនៃព្រះវិហារខ្មែរបុរាណ។ ទោះបីព្រះវិហារនោះតូចក្ដី ក៏ខ្មែរចាត់ទុកព្រះវិហារជាកន្លែងទីសក្ការៈខ្ពង់ខ្ពស់ជាងសំណង់នានាក្នុងវត្ត។[២] ដំបូលនៃព្រះវិហារនេះជាប្រភេទជហ្វា២ដែលមានហោជាងឈើមុខ ក្រោយ មាននាគដងក្ដារ និងមានស្វាបដំបូល២ជាន់ ព្រះវិហារនេះពុំមានល្វែងបាំងសាចទេ។ នៅផ្នែកហោជាងខាងលិច ប្រហែលមានរូបអ្វីនៅចំកណ្ដាលនៃហោជាង ប៉ុន្តែបច្ចុប្បន្ននៅសល់តែទម្រង់នៃរូប ផ្ទៃហោជាងគេឆ្លាក់ជាដើមទំពាំងបាយជូរ នឹងបិទកញ្ចក់រំលេចលម្អលើផ្ទៃនៃហោជាងផង។ ចំពោះសសរខាង

---

[១] ច្បាប់ស្តីពីកិច្ចការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ ១៩៩៦

[២] សូមអាន Giteau 1969.

អត្ថបទដោយ៖ អេង តុលា

ក្រៅ យើងឃើញគេ កសាងចុងសសរជាទម្រង់សសរនៃរចនាបទ Corinthien ដែលជាសិល្បៈក្រិច និងស៊ុមបង្អួចទាំងអស់លម្អជាក្បាច់ទំនងជាសិល្បៈចិន ដែលឆ្លាក់បង្ហាញជារូបសត្វហង្ស និងនាគ។ សសរ ព្រះវិហារខាងក្នុងទាំងអស់សុទ្ធតែជាសសរមូល មានគំនូរទឹបមាស ហើយសសរខ្លះគូរលម្អជាសត្វក្អែក ឯសសរខ្លះទៀតជាក្បាច់ផ្សេងៗ។ ពិដានពុំមានគូរជាគំនូរអ្វីនោះទេប៉ុន្តែផ្ទឹមមានលាបដោយ ម្រ័ក្សណ៍ និងជាតិហិង្គុលរួចមានលម្អគំនូរទឹបមាសពីលើនោះផង។ ហើយជើងតកនៃវិហារនេះក៏ពិសេស មានឆ្លាក់ជាផ្កាឈូក និងលាបពណ៌។ ចំណែកឯបល្ល័ង្គព្រះអង្គដីវិញបង្ហាញជាក្បាច់សម្បុកត្រពាំង[៣] ជំនួសដោយផ្កាឈូក។ នៅផ្នែកខាងក្រោមនៃបល្ល័ង្គមានចម្លាក់លម្អជារូបរាហ៊ូ ផ្នែកខាងក្រោយឃើញមានគំនូរទឹបមាសជាក្បាច់ភ្ញីទេស ភ្ញីវល្លិ៍ និងក្បាច់ផ្សេងៗទៀតផង ។

ព្រះវិហារដែលមានគំនូរទឹកមាសបែបនេះ យើងឃើញមានច្រើននៅតាមតំបន់ដែលនៅតាមបណ្តោយទន្លេមេគង្គ ជាឧទាហរណ៍ខ្លះដូចជានៅ វត្តខ្មែរនេះផ្ទាល់ វត្តចុងព្រែក (រកាកោង) វត្តស្វាយសាច់ភ្នំ (កំពង់ចាម) នឹងវត្តមហាលាភ(កំពង់ចាម) ជាដើម ។

អរិយធម៌ខ្មែរ
KHMER CIVILIZATION

[៣] សូមអាន វ៉ែយំ ក្បាច់ខ្មែរ ២០០៥ ទំ ៤២៩

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ព្រះវិហារចាស់ថតពីចំហៀង



រូបលេខ២៖ ហោជាង៍លម្អក្បាច់ត្រពាំងបាយជូ



រូបលេខ២៣៖ ព្រះវិហារចាស់ថតពីទិសខាងលិច



រូបលេខ២៤-៥៖ សសរមានគំនូររូបក្អែប នឹងដើងគកមានឆ្លាក់ជាផ្កាឈូកនិងលាបពណ៌



រូបលេខ២៦៖ ចម្លាក់រាហ៊ូទ្របល្ល័ងព្រះអង្គជីវ៍



រូបលេខ២៧៖ គំនូរទឹបមាសជាក្បាច់ភ្ញីទេស ភ្ញីល្បើនិងក្បាច់
ផ្នែកខាងក្រោយបល្ល័ង្គព្រះអង្គជីវ៍

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

វៃយំ

២០១៥ ក្បាច់ខ្មែរ ២០០៥

ព្រាប ចាន់ម៉ារ៉ា

យសោធរ គំនូរលើសសរឈើវិហារចាស់ៗ

សាន ផល្លា

២០០៧ គំនូរតាមវត្ត វៃយំ

ច្បាប់ស្ដីពីកិច្ចការការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ ១៩៩៦

Madeleine Giteau

1969 Le bornage rituel des temples bouddhiques au Cambodge, EFEO, Paris

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION